ធ ៩-៩៨-៣៩៣

# ប្រកាស
# ស្ដីពីការគ្រប់គ្រងការប្ដូរប្រាក់
# ចំពោះអាជីវកម្មប្ដូរប្រាក់

ប្រការ ១- បុគ្គល ឬ ក្រុមបុគ្គល អាចធ្វើអាជីវកម្មប្ដូរប្រាក់បាន ទោះស្ថិតក្នុងទីតាំងអចល័ត ឬ ទីតាំងចល័តក្ដី អោយតែទទួលបានការអនុញ្ញាតជាមុនពីធនាគារជាតិនៃកម្ពុជា។បុគ្គលទាំងឡាយណាដែលស្នើសុំទៅធនាគារជាតិនៃកម្ពុជា ដើម្បីធ្វើអាជីវកម្មប្ដូរប្រាក់ ត្រូវមានអាយុចាប់ពី ១៨ ឆ្នាំឡើងទៅ មានទីលំនៅអចិន្ត្រៃយ៍ដែលមានឯកសារបញ្ជាក់ត្រឹមត្រូវដោយអាជ្ញាធរក្នុងមូលដ្ឋានដែលខ្លួនរស់នៅ និង ត្រូវបានអាជ្ញាធរពាក់ព័ន្ធអនុញ្ញាតអំពីទីតាំងអាជីវកម្ម ។

ប្រការ ២- បុគ្គលដែលស្នើសុំធ្វើអាជីវកម្មប្ដូរប្រាក់ ត្រូវបង្ហាញភស្តុតាងថាខ្លួនមានគណនីប្រាក់បញ្ញើជារៀល និង / ឬ គណនីរូបិយប័ណ្ណ សំរាប់បំរើសកម្មភាពអាជីវកម្មនៅធនាគារពាណិជ្ជណាមួយតាមការជ្រើសរើសរបស់ខ្លួន ។ គណនីប្រាក់រៀល ត្រូវតែរក្សាអោយបាននូវសមតុល្យប្រចាំជាមធ្យមស្មើ ប្រាំលាន (៥.០០០.០០០)រៀល ក្នុងខែនីមួយៗ ។ ធនាគារពាណិជ្ជ ដែលរក្សាគណនីខាងលើ ត្រូវធ្វើសំរង់គណនីនៅរាល់ដើមខែ ជូនធនាគារជាតិនៃកម្ពុជា ។

ប្រការ ៣- បុគ្គល ឬ ក្រុមបុគ្គលដែលត្រូវបានទទួលការអនុញ្ញាតអោយប្រកបអាជីវកម្មប្ដូរប្រាក់ តទៅនេះហៅថា « បុគ្គលប្រតិស្រុត » ត្រូវគោរពបទបញ្ជាទាំងឡាយរបស់ធនាគារជាតិនៃកម្ពុជា និងច្បាប់របស់រដ្ឋ ។

ប្រការ ៤- បុគ្គលប្រតិស្រុតត្រូវធ្វើប្រតិបត្តិការប្តូរប្រាក់ក្នុងទីតាំងដែលអាជ្ញាធរមានសមត្ថកិច្ចបានកំណត់ ដោយដាក់បង្ហាញនូវផ្លាកជាអក្សរថា « ប្តូរប្រាក់ » និង អក្សរឡាតាំង « MONEY CHANGER » ព្រមទាំងមាន អាស័យដ្ឋាន « លេខផ្ទះ លេខផ្លូវ » លិខិតអនុញ្ញាតរបស់ធនាគារជាតិនៃកម្ពុជា និង តារាងអត្រាប្តូរប្រាក់ប្រចាំថ្ងៃរបស់ខ្លួន ។

ប្រការ ៥- បុគ្គលប្រតិស្រុតអាចធ្វើបានតែប្រភេទប្រតិបត្តិការទាក់ទងនឹងមធ្យោបាយទូទាត់ជារូបិយប័ណ្ណដូចខាងក្រោម :

១- ទិញក្រដាសប្រាក់ជារូបិយប័ណ្ណ ឬ មូលប្បទានប័ត្រទេសចរណ៍ ដែលអាចទូទាត់ជារូបិយប័ណ្ណ កំពុងមានតំលៃចរាចរជាអន្តរជាតិ ។

២- លក់ក្រដាសប្រាក់ជារូបិយប័ណ្ណ ឬ មូលប្បទានប័ត្រទេសចរណ៍ជារូបិយប័ណ្ណអោយធនាគារជាតិនៃកម្ពុជា ឬ ធនាគារពាណិជ្ជ

- ឬ ដាក់ផ្ញើក្នុងគណនីរបស់ខ្លួននៅធនាគារពាណិជ្ជ
- លក់រូបិយប័ណ្ណដោយបង្វែរគណនីអោយអ្នកនាំទំនិញចូល
- លក់រូបិយប័ណ្ណអោយបុគ្គលដែលមានទិដ្ឋាការអនុញ្ញាតអោយទៅបរទេស តាមចំនួនប្រាក់ខ្ពស់បំផុតមិនលើសពី ប្រាំពាន់ (៥.០០០) ដុល្លារអាមេរិក ក្នុងម្នាក់ៗ ក្រោយពីបានបង្ហាញឯកសារពាក់ព័ន្ធដល់ការធ្វើដំណើរទៅបរទេស
- លក់រូបិយប័ណ្ណអោយភ្ញៀវបរទេសដែលមានវិញ្ញាបនប័ត្របញ្ជាក់ថាបានប្តូរប្រាក់ពេលចូលមកកម្ពុជា ប៉ុន្តែចំណាយមិនទាន់អស់ នៅពេលត្រឡប់ទៅវិញ
- លក់រូបិយប័ណ្ណដល់បុគ្គលដទៃទៀត ក្នុងចំនួនប្រាក់មិនលើសពី បីរយ (៣០០) ដុល្លារអាមេរិក ។

ប្រការ ៦- ក្នុងការទិញលក់រូបិយប័ណ្ណ បុគ្គលប្រតិស្រុតត្រូវបំពេញវិញ្ញាបនប័ត្រប្តូរប្រាក់តាមគំរូ ណែនាំដោយធនាគារជាតិនៃកម្ពុជា ក្នុងនោះត្រូវមានលំអិតលេខមាលា (Série) កាលបរិច្ឆេទ ទិញ - លក់, ឈ្មោះ និង អាស័យដ្ឋាននៃអ្នកទិញ / អ្នកលក់, ចំនួនទឹកប្រាក់ជារូបិយប័ណ្ណ, ប្រភេទរូបិយប័ណ្ណ, អត្រាប្តូរប្រាក់, ចំនួនទឹកប្រាក់រៀល និងមានហត្ថលេខាបុគ្គលប្រតិស្រុត ឬ អ្នកតំណាង ។

ប្រការ ៧- រាល់លើកនៃការទិញ- លក់ បុគ្គលប្រតិស្រុតត្រូវចេញវិញ្ញាបនប័ត្រ ជាពីរច្បាប់ ក្នុងនោះច្បាប់ដើមត្រូវប្រគល់អោយអតិថិជន រីឯច្បាប់ចំលងត្រូវរក្សាទុកសំរាប់កត់ត្រាក្នុងសៀវភៅបញ្ជីប្រចាំថ្ងៃរបស់ខ្លួន ។

ប្រការ ៨- បុគ្គលប្រតិស្រុតមិនអនុញ្ញាតអោយធ្វើសកម្មភាពទទួលប្រាក់បញ្ញើ ឬ អោយខ្ចី ចងការ ឬ សកម្មភាពដទៃទៀតដែលពាក់ព័ន្ធដល់សកម្មភាពអាជីវកម្មធនាគារពាណិជ្ជ ឡើយ ។

ប្រការ ៩- បុគ្គលប្រតិស្រុតត្រូវរក្សាអោយបានត្រឹមត្រូវនូវសៀវភៅបញ្ជីនៃគ្រប់ប្រតិបត្តិការទិញ - លក់រូបិយប័ណ្ណ និងមូល្យទានប័ត្រទេសចរណ៍អាចទូទាត់បានជារូបិយប័ណ្ណ។ សៀវភៅបញ្ជីព្រមទាំងឯកសារទិញ- លក់ដូចមានចែងខាងលើត្រូវថែរក្សាទុក នៅទីតាំងប្តូរប្រាក់របស់ខ្លួននិងត្រូវរៀបរយជាស្រេច ដើម្បីបង្ហាញជូនភ្នាក់ងារធនាគារជាតិនៃកម្ពុជា នៅរាល់អធិការកិច្ចតាមគ្រាកំណត់ ឬ ដោយចៃដន្យ ( ដោយមិនមានការជូនដំណឹងជាមុន ) ។

ប្រការ ១០- បុគ្គលប្រតិស្រុតត្រូវធ្វើរបាយការណ៍អំពីប្រតិបត្តិការនិងស្ថានភាពរូបិយប័ណ្ណប្រចាំសប្តាហ៍និមួយៗ ជូនធនាគារជាតិនៃកម្ពុជា (នាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់) នៅរៀងរាល់ ថ្ងៃអង្គារ នៃសប្តាហ៍បន្ទាប់ ។ ប្រតិបត្តិការប្តូរប្រាក់ប្រចាំថ្ងៃត្រូវចុះលំអិតក្នុងរបាយការណ៍ ។ ចំពោះថ្ងៃដែលពុំមានសកម្មភាពប្តូរប្រាក់ ត្រូវកត់ត្រាថា"គ្មាន"។ ក្នុងរបាយការណ៍ត្រូវតែបញ្ជាក់អំពីសមតុល្យ "សំណល់ "រូបិយប័ណ្ណនៅចុងថ្ងៃនៃសប្តាហ៍និមួយៗ ។

ប្រការ ១១- លិខិតអនុញ្ញាតធ្វើអាជីវកម្មប្តូរប្រាក់ ដែលចេញផ្សាយដោយធនាគារជាតិនៃកម្ពុជាមានតំលៃសុពលភាពរយៈពេល ១២ ខែ ។បុគ្គលប្រតិស្រុតដែលចង់បន្តអាជីវកម្មរបស់ខ្លួនត្រូវដាក់ពាក្យសុំជាថ្មីក្នុងរយៈពេល ៣០ថ្ងៃ មុនថ្ងៃផុតកំណត់សុពលភាព ។

ប្រការ ១២- លិខិតអនុញ្ញាតអាចត្រូវដកហូតវិញបាន ក្នុងករណីដែលបុគ្គលប្រតិស្រុតបានប្រព្រឹត្តល្មើសនូវបទបញ្ញត្តិនិងបទបញ្ញត្តិផ្សេងៗ ដូចខាងក្រោម :

- មិនបង់ប្រាក់ពន្ធអាករផ្សេងៗ ក្រោយពេលធនាគារជាតិបានទទួលដំណឹងជាផ្លូវការ និងជាលាយលក្ខអក្សរពីស្ថាប័នមានសមត្ថកិច្ច
- មិនធ្វើរបាយការណ៍ប្រចាំសប្តាហ៍ជូនធនាគារជាតិរយៈពេល ១ ខែ
- មិនតាំងបង្ហាញលិខិតអនុញ្ញាត និង អត្រាប្តូរប្រាក់ប្រចាំថ្ងៃរបស់ខ្លួន

- មិនបានបំពេញ ឬ រក្សាវិញ្ញាបនប័ត្រប្តូរប្រាក់ សៀវភៅបញ្ជីកត់ត្រាប្រតិបត្តិការ និង មិនបង្កលក្ខណៈងាយស្រួលដល់ការធ្វើអធិការកិច្ចរបស់ភ្នាក់ងារ ធនាគារជាតិនៃកម្ពុជា
- មិនបង្ហាញអោយដឹងនូវកិច្ចការជំនួញរបស់ខ្លួន ក្នុងបំណងលាក់បំបាំងដើម្បីទទួលបាន ប្រាក់ចំណេញហួសហេតុ ឬ រក្សាទុករូបិយប័ណ្ណក្នុងគោលដៅធ្វើវិច្ឆេទកម្ម ឬ សំរាប់ គោលបំណងទុច្ចរិតផ្សេងៗទៀត
- ប្រព្រឹត្តនូវសកម្មភាពផ្សេងៗដែលផ្ទុយនឹងច្បាប់របស់រដ្ឋ ។

ប្រការ ១៣- ករណីផ្អាក ឬ បញ្ឈប់សកម្មភាព ឬ ប្តូរទីតាំងធ្វើអាជីវកម្ម បុគ្គលប្រតិស្រុតត្រូវ ដាក់សំណើជាលាយលក្ខអក្សរ ដោយភ្ជាប់នូវសំណុំឯកសារពាក់ព័ន្ធមកធនាគារជាតិ ក្នុងរយៈពេល ៣០ថ្ងៃមុន ដើម្បីសុំសេចក្តីសំរេច ។

ប្រការ ១៤- បុគ្គលប្រតិស្រុតដែលលាក់បំបាំងពត៌មាន ឬ ផ្តល់ពត៌មានអំពីប្រតិបត្តិការរបស់ ខ្លួនមិនច្បាស់លាស់ នឹងត្រូវផ្តន្ទាទោសតាមមាត្រា ៦៩ នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ ធនាគារជាតិនៃកម្ពុជា ។

ប្រការ ១៥- បុគ្គលដែលធ្វើអាជីវកម្មប្តូរប្រាក់ដោយគ្មានការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា នឹងត្រូវផ្តន្ទាទោសតាមមាត្រា ២១ នៃច្បាប់ស្តីពីការគ្រប់គ្រងការប្តូរប្រាក់ ។

ប្រការ ១៦- ការិយាល័យប្តូរប្រាក់ ឬបញ្ជរប្តូរប្រាក់របស់ធនាគារពាណិជ្ជមិនស្ថិតក្នុងក្របខ័ណ្ឌ នៃប្រកាសនេះឡើយ។

ប្រការ ១៧- ប្រកាសទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍ ។

ប្រការ ១៨- អគ្គលេខាធិការ - អគ្គនាយក- អគ្គពិនិត្យ - អគ្គបេឡា - នាយកដ្ឋានគ្រប់គ្រង ការប្តូរប្រាក់ និងគ្រប់នាយកដ្ឋានពាក់ព័ន្ធក្រោមឱវាទធនាគារជាតិមានភារកិច្ចអនុវត្តរៀងៗ ខ្លួនតាមប្រកាសនេះ ។

ប្រការ ១៩- ប្រកាសនេះមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែ សីហា ឆ្នាំ១៩៩៨

ហត្ថលេខា និងត្រា **ជា ចាន់តូ**